ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ៖ ៦២២
ចុះថ្ងៃទី០៤-០៦-២០១៨

**សាលដីកា**
លេខ៖ ១០០ "ក្រ.v.ច"
ចុះថ្ងៃទី២២-០៨-២០២២

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈនស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦-០៧-២០១៤ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ថ្ងៃទី២៩-០៧-២០២២ ដោយមានសមាសភាពដូចតទៅៈ

### សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា
ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

### ក្រឡាបញ្ជី

លោក [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៦២២ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ ដោយមាន៖

**១-ជនជាប់ចោទ**ឈ្មោះ [redacted] **ថាត** ភេទប្រុស អាយុ៥៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរធ្វើចំការ ទីកន្លែងកំណើតភូមិក្រូចឆ្មា ឃុំក្រូចឆ្មា ស្រុកក្រូចឆ្មា ខេត្តកំពង់ចាម មានទីលំនៅសព្វថ្ងៃ ភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] "រស់" ម្តាយឈ្មោះ [redacted] ហេង "ស្លាប់" ស្ថានភាពគ្រួសារប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៣ នាក់ ទោសពីមុន គ្មាន ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣១៩ ត.ព ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ ។

-មេធាវីការពារសិទ្ធិជនជាប់ចោទដោយមេធាវី [redacted] សុខហេង ។

**២-ជនជាប់ចោទ**ឈ្មោះ [redacted] **ឡឿន** ភេទប្រុស អាយុ៤៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនា





CamScanner

ព្រះពុទ្ធ ទីកន្លែងកំណើតភូមិព្រៀសលើ ឃុំតាសែន ស្រុកទាំងខេត្តតាកែវ មានទីលំនៅសព្វថ្ងៃ ភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] "ស្លាប់ ម្ដាយឈ្មោះ [redacted] "រស់ ស្ថានភាពគ្រួសារប្រពន្ធឈ្មោះ [redacted] (លែងលះ) មានកូនចំនួន ០៣ នាក់ ទោសពីមុនគ្មាន ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣១៩ ត.ព ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧ ។

-មេធាវីការពារសិទ្ធិជនជាប់ចោទដោយមេធាវី [redacted] លក្ខិណា ។

-ជាប់ចោទពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចភូមិស្រឡៅទង ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ ៧ ចំណុច ៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ៦រឿងហេតុមានដូចតទៅ:

កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ វេលាម៉ោង ១២ និង ៣០ នាទីកម្លាំងប្រឆាំងគ្រឿងញៀនសហការជាមួយកម្លាំងការិយាល័យប្រឆាំងគ្រឿងញៀននៃស្នងការនគរបាលខេត្តបាត់ដំបង បានចុះប្រតិបត្តិការបង្ក្រាបករណីជួញដូរគ្រឿងញៀននៅចំណុចភូមិស្រឡៅទង ឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង ដោយឃាត់ខ្លួនបានជនជាប់ចោទបានចំនួន ០២នាក់ មានឈ្មោះ [redacted] នឿន ភេទប្រុស និងឈ្មោះ [redacted] ថាត ភេទប្រុស ហើយបានដកហូតថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ម៉ាទឹកកកICE) ចំនួន ១០ ថង់ធំ ទម្ងន់ ៩៧៦,៧០ ក្រាម និង យ៉ាម៉ាគ្រាប់ចំនួន ៤៨ ថង់ ក្នុងនោះមាន ៩៥៧២ គ្រាប់ ទម្ងន់ ៨៨៩,៦០ ក្រាម ពីជនជាប់ចោទទាំងពីរនាក់ ។ ថ្នាំញៀននេះជនជាប់ចោទឈ្មោះ [redacted] ថាត បានទិញពីឈ្មោះ ណាក់ អ្នករត់ម៉ូតូឌុប ហើយយកមកលក់ឲ្យឈ្មោះ [redacted] នឿន តាមការកុម្ម៉ង់ទិញ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៧៣ "ដ" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១-ផ្ដន្ទាទោសលើជនជាប់ចោទ ៖

១.១/ ឈ្មោ [redacted] នឿន ភេទប្រុស ៤៥ ឆ្នាំ

១.២/ ឈ្មោះ [redacted] ថាត ភេទប្រុស ៥៣ ឆ្នាំ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗរយៈពេល ២០ (ម្ភៃ) ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួន និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល បង់ចូលថវិការរដ្ឋ ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ភូមិស្រឡៅទង ឃុំកំរៀង ស្រុកកំរៀង ខត្តបាត់ដំបង កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងញផ្ដន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៧ ចំណុចទី៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

២/វត្ថុតាងចាប់យករួមមាន ៖

- ទូរស័ព្ទម៉ាកអិនចុចពិល ចំនួន ០១ គ្រឿង រឹបអូសជាសម្បត្តិរដ្ឋ ។
- សារធាតុញៀនឈ្មោះ មេតំហ្វេតាមីន មានទម្ងន់សរុប ៣៨៨.៨៩ ក្រាម រឹបអូសបំផ្លាញចោល ។

៣/សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] នឿន និងឈ្មោះ[redacted]ថាត និងប្រកាសជាសាធារណៈនៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ ។

-**បានឃើញ** សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខ ២១ , ២២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] នឿន និងឈ្មោះ [redacted] ថាត សុំប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧៣ "ដ" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-**បានឃើញ** របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍។

-**បានឃើញ** សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

## **<u>នាពេលសវនាការ</u>**

## **ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង**

ជនជាប់ចោទឈ្មោះ[redacted] ថាត ថា ថ្នាំញៀនខ្លួនបានពីឈ្មោះ ណាក់ ទៅលក់ឲ្យឈ្មោះ នឿន តម្លៃភ្លេចបាត់ ចំណេញបានប៉ុន្មានមិនចាំទេ ប្រព្រឹត្តបែបនេះដោយសារ ខ្វះខាត មានជម្ងឺទឹកផ្អែម ខ្លួនដឹងកំហុសហើយ ឈប់ប្រព្រឹត្តទៀតហើយ សុំបន្ធូរបន្ថយទោស ។

ជនជាប់ចោទឈ្មោះ[redacted]នឿន ថា ខ្លួនទិញថ្នាំញៀនពីឈ្មោះ ថាត អ្នកចាំទទួលបន្តឈ្មោះ គីម ប្ដឹងឧទ្ធរណ៍ដោយសារច្រើនពេក ដឹងកំហុសហើយ សុំបន្ធូរបន្ថយទោស ។

## **តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋាន**

បណ្ដឹងឧទ្ធរណ៍របស់ជនជាប់ចោទមានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ យោងតាមមាត្រា ៣៧៥ , ៣៨២ (ថ្មី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ជនជាប់ចោទបានសារភាព ប្ដឹងឧទ្ធរណ៍គ្រាន់តែសុំបន្ធូរបន្ថយ ការដាក់ទណ្ឌកម្មត្រឹមត្រូវហើយ សុំតម្កល់ទុកជាបានការដដែល ។

**<u>សេចក្ដីសន្និដ្ឋានមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ សោម ថាត</u>**

កូនក្ដីខ្លួនបានសារភាពហើយ កូនក្ដីខ្លួនមានអាយុច្រើន មានជម្ងឺប្រចាំកាយ បានដឹងកំហុសហើយ សុំក្រុមប្រឹក្សាពិចារណាបន្ធូរបន្ថយទោស ។

**<u>សេចក្ដីសន្និដ្ឋានមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ សោម នឿន</u>**

កូនក្ដីខ្លួនបានសារភាពហើយ កូនក្ដីខ្លួនមានអាយុច្រើន ដឹងកំហុសហើយ សុំក្រុមប្រឹក្សាពិចារណាបន្ធូរ បន្ថយទោស ។

## **តុលាការថយទៅពិភាក្សា**

ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ

ក្រោយពីបានស្ដាប់អំណានរបាយការណ៍

ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី



CS CamScanner

ក្រោយពីបានស្តាប់តំណាងមហាអយ្យការធ្វើសន្និដ្ឋាន
ក្រោយពីបានស្តាប់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទធ្វើសន្និដ្ឋាន
ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ។

## សាលាឧទ្ធរណ៍

**យល់ឃើញថា:**

១-សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ២១ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] ចាត និងសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] នឿន ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧៣ "ដ" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងតាមមាត្រា ៣៧៥ , ៣៨២ (ថ្មី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ[redacted] ចាត ថា ថ្នាំញៀនខ្លួនបានពីឈ្មោះ ណាក់ ទៅលក់ឲ្យឈ្មោះ នឿន តម្លៃ ភ្លេចបាត់ ចំណេញបានប៉ុន្មានមិនចាំទេ ប្រព្រឹត្តបែបនេះដោយសារ ខ្វះខាត មានជម្ងឺទឹកផ្អែម ខ្លួនដឹងកំហុស ហើយ ឈប់ប្រព្រឹត្តទៀតហើយ សុំបន្ធូរបន្ថយទោស ។

៣-ជនជាប់ចោទឈ្មោះ[redacted] នឿន ថា ខ្លួនទិញថ្នាំញៀនពីឈ្មោះ ចាត អ្នកចាំទទួលបន្តឈ្មោះ គីម ប្តឹងឧទ្ធរណ៍ដោយសារច្រើនពេក ដឹងកំហុសហើយ សុំបន្ធូរបន្ថយទោស ។

៤-តំណាងមហាអយ្យការបានសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោ[redacted]ចាត និងឈ្មោះ[redacted] នឿន ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៧៥ , ៣៨២ (ថ្មី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ជនជាប់ចោទបានសារភាព ប្តឹងឧទ្ធរណ៍គ្រាន់តែសុំបន្ធូរបន្ថយ ការ ដាក់ទណ្ឌកម្មត្រឹមត្រូវហើយ សុំតម្កល់ទុកជាបានការដដែល ។ សាលាឧទ្ធរណ៍យល់ឃើញថា ការសន្និដ្ឋាន របស់តំណាងមហាអយ្យការមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៥-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានសន្និដ្ឋានថា កូនក្តីខ្លួនឈ្មោ[redacted]ចាត បានសារភាព ហើយ កូនក្តីខ្លួនមានអាយុច្រើន មានជម្ងឺប្រចាំកាយ បានដឹងកំហុសហើយ សុំក្រុមប្រឹក្សាពិចារណាបន្ធូរបន្ថយ ទោស ។

៦-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានសន្និដ្ឋានថា កូនក្តីខ្លួនឈ្មោះ[redacted]ឿន បានសារភាព ហើយ កូនក្តីខ្លួនបានសារភាពហើយ កូនក្តីខ្លួនមានអាយុច្រើន ដឹងកំហុសហើយ សុំក្រុមប្រឹក្សាពិចារណាបន្ធូរបន្ថយទោស ។

៧-ការសន្និដ្ឋានរបស់មេធាវីសុំឲ្យសាលាឧទ្ធរណ៍ភ្នំពេញ បន្ធូរបន្ថយទោសលើជនជាប់ចោទឈ្មោះ [redacted] ចាត និងឈ្មោះ [redacted] នឿន ដោយលើកហេតុផលថា បានសារភាព និងដឹងពីកំហុស សាលាឧទ្ធរណ៍យល់ឃើញថា ការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទពុំមាន សំអាងហេតុណាមួយមកបញ្ជាក់ជូនសាលាឧទ្ធរណ៍ពិចារណាបន្ធូរបន្ថយទោសឡើយ ។ ការដាក់ទណ្ឌកម្មមានលក្ខណៈសមល្មមហើយ ទៅនឹងភស្តុតាងដែលសមត្ថកិច្ចចាប់ដកហូតបាន ។



CamScanner

៨-សាលក្រមព្រហ្មទណ្ឌលេខ ១៧៣ "ដ" ចុះថ្ងៃទី២១ ខែ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបាត់ដំបង បានសម្រេចសេចក្តីមានលក្ខណៈត្រឹមត្រូវហើយ គប្បីសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រម នេះទុកជាបានការដដែល ។

**ហេតុដូច្នេះ**
**វិនិច្ឆ័យសេចក្តី**

១)ក.ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ២១ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ[redacted]ថាត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

ខ.ទទួលសេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ ២២ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ[redacted] នឿន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២).តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៧៣ "ដ" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការ ។

៣).បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ[redacted] ថាត និងឈ្មោះ[redacted] នឿន តាមនីតិវិធីច្បាប់ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា[redacted] | ហត្ថលេខា[redacted] | ហត្ថលេខា:[redacted] |

---

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ............ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

សាលាឧទ្ធរណ៍ភ្នំពេញ ថ្ងៃទី.........ខែ.........ឆ្នាំ២០២២

បានឃើញ
**ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]